ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា
លេខ: ០០៩/២៣ ន.ម.ក./គ.ណ.ន.

# គោលការណ៍ណែនាំ
# ស្តីពី
# បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ប្រកាសលេខ ០៣៧ អ.ស.ហ.ប្រក ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ, និងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធ និងដើម្បីជំរុញនវានុវត្តន៍នៅក្នុងវិស័យមូលបត្រនិងធានាបាននូវការគ្រប់គ្រងនិងការត្រួតពិនិត្យលើការសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្ថិតក្រោមឬអាចនឹងស្ថិតក្រោមនិយ័តកម្មរបស់និយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) **ន.ម.ក.** រៀបចំគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ ដែលកំណត់ពីគោលដៅ គោលការណ៍ លក្ខខណ្ឌវិនិច្ឆ័យ នីតិវិធីនៃការដាក់ពាក្យស្នើសុំ លក្ខខណ្ឌតម្រូវសម្រាប់ការអនុញ្ញាតចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ កាតព្វកិច្ចក្នុងដំណាក់កាលសាកល្បង កាតព្វកិច្ចបន្ទាប់ពីដំណាក់កាលសាកល្បង និងព័ត៌មានដែលត្រូវផ្តល់ជូន **ន.ម.ក.**។

**ន.ម.ក.** សម្រេចចេញគោលការណ៍ណែនាំស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ ដើម្បីអនុវត្តប្រកាសលេខ០៣៧ អ.ស.ហ.ប្រក ខាងលើ ឱ្យមានប្រសិទ្ធភាពខ្ពស់ អនុលោមតាមច្បាប់ជាធរមាន ជំនួសគោលការណ៍ណែនាំលេខ ០០១/២២ ន.ម.ក./គ.ណ.ន. ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២២ ស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ ដូចខាងក្រោម៖

## ១-នីតិវិធីនៃការដាក់ពាក្យស្នើសុំការអនុញ្ញាត

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ សំដៅដល់បរិស្ថានសម្រាប់ឱ្យក្រុមហ៊ុនសាកល្បងនូវផលិតផលនិងសេវាកម្មហិរញ្ញវត្ថុរបស់ខ្លួនជាមួយនឹងអតិថិជនពិតប្រាកដ ប៉ុន្តែក្នុងលំហ (Space) និង

អាសយដ្ឋាន : អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា
Address : Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611
E-mail : info@serc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622
Website: www.serc.gov.kh

រយៈពេលកំណត់មួយ មុននឹងធ្វើការដាក់ចេញ និងការពង្រីកការប្រើប្រាស់ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុនោះឱ្យបានទូលំទូលាយ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

បុគ្គលដែលមានបំណងប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុតាមបែបនវានុវត្តន៍ក្នុងការផ្តល់ផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្ថិតក្រោម ឬអាចនឹងស្ថិតក្រោមនិយ័តកម្មរបស់ **ន.ម.ក.** ត្រូវដាក់ពាក្យស្នើសុំ និងទទួលបានការអនុញ្ញាតជាមុន ដើម្បីចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (តទៅហៅថា "បុគ្គលដាក់ពាក្យស្នើសុំ") ស្របតាមគោលការណ៍ណែនាំនេះ ដើម្បីសាកល្បងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលមាននវានុវត្តន៍នៅក្នុងបរិស្ថានផលិតកម្ម ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងជាក់លាក់ និងក្នុងរយៈពេលកំណត់មួយ។ ការស្នើសុំការអនុញ្ញាតគឺត្រូវធ្វើឡើងស្របតាមទម្រង់បែបបទ និងត្រូវភ្ជាប់មកជាមួយនូវឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ក.**។ ដ្យាក្រាមនៃនីតិវិធីនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ មាននៅក្នុងឧបសម្ព័ន្ធ១ នៃគោលការណ៍ណែនាំនេះ។ ដើម្បីទទួលបានការអនុញ្ញាតចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញតាមលក្ខខណ្ឌគោលដៅ គោលការណ៍ និងលក្ខខណ្ឌវិនិច្ឆ័យវាយតម្លៃដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំនេះ។

នៅក្នុងដំណាក់កាលដាក់ពាក្យស្នើសុំ **ន.ម.ក.** នឹងពិនិត្យពាក្យស្នើសុំ និងជូនដំណឹងអំពីភាពសមស្របនៃការស្នើសុំរបស់បុគ្គលដាក់ពាក្យស្នើសុំសម្រាប់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពី **ន.ម.ក.** ទទួលបានឯកសារពាក់ព័ន្ធពេញលេញដែលចាំបាច់សម្រាប់ការវាយតម្លៃ។

នៅក្នុងដំណាក់កាលវាយតម្លៃ រយៈពេលនៃការវាយតម្លៃពាក្យស្នើសុំ ត្រូវបានកំណត់អាស្រ័យលើភាពពេញលេញ ភាពស្មុគស្មាញ និងលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិពាក់ព័ន្ធ។ បុគ្គលដាក់ពាក្យស្នើសុំអាចស្នើសុំកែតម្រូវនិងដាក់ពាក្យស្នើសុំឡើងវិញ បន្ទាប់ពីបានពិភាក្សាជាមួយ **ន.ម.ក.**។ **ន.ម.ក.** នឹងចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងក្នុងដំណាក់កាលនេះ។

**ន.ម.ក.** នឹងជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីការយល់ព្រម ឬបដិសេធលើការស្នើសុំនេះ។ **ន.ម.ក.** អាចបដិសេធការស្នើសុំរបស់បុគ្គលដាក់ពាក្យស្នើសុំ ក្នុងករណីបុគ្គលដាក់ពាក្យស្នើសុំមិនអាចបំពេញតាមលក្ខខណ្ឌគោលដៅ ឬគោលការណ៍ ឬលក្ខខណ្ឌវិនិច្ឆ័យវាយតម្លៃណាមួយនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ឬការតម្រូវរបស់ **ន.ម.ក.**។

ក្នុងករណីការស្នើសុំត្រូវបានបដិសេធ បុគ្គលដាក់ពាក្យស្នើសុំអាចដាក់ពាក្យស្នើសុំឡើងវិញនៅពេលដែលអាចបំពេញតាមលក្ខខណ្ឌគោលបំណង គោលការណ៍ លក្ខខណ្ឌវិនិច្ឆ័យវាយតម្លៃនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងការតម្រូវរបស់ **ន.ម.ក.**។

នៅពេលទទួលបានការអនុញ្ញាតចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ បុគ្គលដាក់ពាក្យស្នើសុំក្លាយជាបុគ្គលទទួលខុសត្រូវលើការដាក់ឱ្យដំណើរការ និងធ្វើប្រតិបត្តិការបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ (តទៅហៅថា "បុគ្គលបរិស្ថានសាកល្បង")។

ករណីបុគ្គលបរិស្ថានសាកល្បងមានបំណងកែប្រែជាសារវន្តនូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលកំពុងសាកល្បងក្នុងដំណាក់កាលសាកល្បង បុគ្គលបរិស្ថានសាកល្បងត្រូវ ស្នើសុំការអនុញ្ញាតជាមុនមក **ន.ម.ក.** ដោយត្រូវផ្តល់ព័ត៌មានលម្អិត និងមូលហេតុនៃការកែប្រែ។ បុគ្គលបរិស្ថានសាកល្បងនៅតែអាចបន្តសាកល្បងទៅតាមលក្ខខណ្ឌនៃការអនុញ្ញាតដែលមានស្រាប់ ក្នុងអំឡុងពេលដែល **ន.ម.ក.** កំពុងពិនិត្យការស្នើសុំកែប្រែ។

ក្នុងករណីចាំបាច់ **ន.ម.ក.** អាចផ្សព្វផ្សាយនៅលើគេហទំព័ររបស់ **ន.ម.ក.** និង/ឬមធ្យោបាយផ្សេងទៀត នូវព័ត៌មានពាក់ព័ន្ធនឹងការស្នើសុំចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលទទួលបានការអនុញ្ញាត ដូចជា ឈ្មោះរបស់ក្រុមហ៊ុន កាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបញ្ចប់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុជាដើម។

## ២-សុពលភាពនៃការអនុញ្ញាត

សុពលភាពនៃការអនុញ្ញាតត្រូវកំណត់ដោយ **ន.ម.ក.** ដោយផ្អែកទៅលើភាពជាក់ស្តែង ភាពស្មុគស្មាញនិងតម្រូវការនៃការសាកល្បងនៃផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង។ ក្នុងករណីមានតម្រូវចាំបាច់លើពេលវេលាបន្ថែមក្នុងការសាកល្បង បុគ្គលបរិស្ថានសាកល្បងអាចស្នើសុំការអនុញ្ញាតពន្យារពេលមក **ន.ម.ក.** យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃការអនុញ្ញាត និងត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំពន្យារនេះ។ **ន.ម.ក.** នឹងពិនិត្យការស្នើសុំនេះ ដោយពិចារណាផ្តល់ការអនុញ្ញាតទៅតាមករណីនីមួយៗ។

## ៣-គោលដៅនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុមានគោលដៅជួយជំរុញការសាកល្បងបច្ចេកវិទ្យាហិរញ្ញ-វត្ថុដែលស្ថិតក្រោមការគ្រប់គ្រងជាក់លាក់ និងក្នុងរយៈពេលកំណត់មួយ ដើម្បី៖

ក- បង្កើននូវប្រសិទ្ធភាព។

ខ- គ្រប់គ្រងហានិភ័យឱ្យកាន់តែល្អប្រសើរ។

គ- បង្កើតកាលានុវត្តភាពថ្មី។

ឃ- ធ្វើឱ្យការរស់នៅរបស់ប្រជាជនកាន់តែល្អប្រសើរ។

## ៤-គោលការណ៍នៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុមានគោលការណ៍ដូចខាងក្រោម៖

ក- មិនមានភាពស្រដៀងគ្នាទៅនឹងផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានស្រាប់នៅក្នុងវិស័យមូលបត្រ។

ខ- មាននវានុវត្តន៍ដែលបង្កើតជាតម្លៃបន្ថែមដល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលមានស្រាប់នៅក្នុងវិស័យមូលបត្រ។

គ- ផ្តល់អត្ថប្រយោជន៍ដែលអាចកំណត់បាន ដោយផ្ទាល់ ឬដោយប្រយោលដល់អតិថិជន ឬវិស័យមូលបត្រ។

ឃ- មានលំហ និងរយៈពេលសម្រាប់សាកល្បងជាក់លាក់។

ង- អាចគ្រប់គ្រងបាននូវហានិភ័យ និងផលវិបាកដែលកើតចេញពីការបរាជ័យនៃការសាកល្បង។

ច- ត្រូវបំពេញកាតព្វកិច្ចតាមច្បាប់ ដោយរួមបញ្ចូលទាំងការធ្វើការសាកល្បងផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើងនៅក្នុងបរិស្ថានសាកល្បង និងការយល់ដឹងអំពីលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ ដើម្បីផ្តល់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង។

## ៥-លក្ខខណ្ឌវិនិច្ឆ័យវាយតម្លៃនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

លក្ខខណ្ឌវិនិច្ឆ័យវាយតម្លៃនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង ប្រើប្រាស់បច្ចេកវិទ្យាថ្មីឬទើបកើតមានឡើង ឬប្រើប្រាស់បច្ចេកវិទ្យាដែលមានស្រាប់តាមរបៀបនវានុវត្តន៍។

ខ- ផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង អាចដោះស្រាយបញ្ហា ឬផ្តល់ជាអត្ថប្រយោជន៍ដល់អ្នកប្រើប្រាស់ ឬឧស្សាហកម្មហិរញ្ញវត្ថុ។

គ- បុគ្គលដាក់ពាក្យស្នើសុំត្រូវជាក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានឆន្ទៈ មានធនធាន និងមានសមត្ថភាពដាក់ឱ្យប្រើប្រាស់នូវផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងកម្រិតទូលំទូលាយ បន្ទាប់ពីចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ឃ- បុគ្គលដាក់ពាក្យស្នើសុំត្រូវកំណត់ឱ្យបានច្បាស់លាស់នូវសេណារីយ៉ូសាកល្បង និងលទ្ធផលរំពឹងទុកនៃការសាកល្បងនៅក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ង- បុគ្គលដាក់ពាក្យស្នើសុំត្រូវកំណត់លក្ខខណ្ឌវិសាលភាពសមស្របឱ្យបានច្បាស់លាស់ ដើម្បីឱ្យបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុអាចធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព អាចការពារនូវផលប្រយោជន៍អ្នកប្រើប្រាស់ និងអាចរក្សាបាននូវសុវត្ថិភាពនិងភាពរឹងមាំនៃឧស្សាហកម្មហិរញ្ញវត្ថុ។

ច- បុគ្គលដាក់ពាក្យស្នើសុំត្រូវពិនិត្យវាយតម្លៃ និងកាត់បន្ថយហានិភ័យសំខាន់ៗដែលអាចកើតចេញពីផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង។

ឆ- បុគ្គលដាក់ពាក្យស្នើសុំត្រូវមានវិធាន គោលការណ៍និងគោលនយោបាយចាំបាច់ផ្សេងៗសម្រាប់ប្រតិបត្តិការនៃផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង។

ជ- បុគ្គលដាក់ពាក្យស្នើសុំត្រូវកំណត់យុទ្ធសាស្ត្រចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុដែលអាចទទួលយកបាន ក្នុងករណីផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង ត្រូវបានបញ្ឈប់ ឬអាចបន្តឈានទៅដល់ការដាក់ឱ្យប្រើប្រាស់ក្នុងកម្រិតទូលំទូលាយបន្ទាប់ពីចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

ឈ- បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌផ្សេងទៀតដែលកំណត់ដោយ **ន.ម.ក.**។

## ៦-អញ្ញត្រកម្មបទប្បញ្ញត្តិ

ដើម្បីជំរុញឱ្យមាននវានុវត្តន៍ **ន.ម.ក.** នឹងពិចារណាបន្ធូរបន្ថយ ឬលើកលែងលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ ដែលអាចក្នុងទម្រង់ជាការលើកលែងលក្ខណៈទូលំទូលាយ ឬជាការលើកលែងជាក់លាក់ណាមួយតាមករណីជាក់ស្តែងនីមួយៗ សម្រាប់រយៈពេលនៃការសាកល្បង ដោយអាស្រ័យលើផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលជាកម្មវត្ថុនៃការសាកល្បង បុគ្គលដាក់ពាក្យស្នើសុំ និងការស្នើសុំរបស់បុគ្គលដាក់ពាក្យស្នើសុំ។ គំរូនៃលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិដែលអាចត្រូវបានពិចារណាបន្ធូរបន្ថយ និងគំរូនៃលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិដែលតម្រូវឱ្យបន្តអនុវត្ត មាននៅក្នុងឧបសម្ព័ន្ធ២ នៃគោលការណ៍ណែនាំនេះ។

បន្ទាប់ពីការសាកល្បងទទួលបានជោគជ័យ និងចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ បុគ្គលបរិស្ថានសាកល្បងត្រូវគោរពតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិពាក់ព័ន្ធឱ្យបានពេញលេញ។

## ៧-ភារកិច្ចក្នុងដំណាក់កាលសាកល្បង

ក្នុងដំណាក់កាលសាកល្បង **ន.ម.ក.** អាចតម្រូវឱ្យបុគ្គលបរិស្ថានសាកល្បងផ្តល់ព័ត៌មាន និងរបាយការណ៍ដូចខាងក្រោម៖

ក- សូចនាករសមិទ្ធកម្មគន្លឹះ វឌ្ឍនភាពនៃការសាកល្បង ព្រឹត្តិការណ៍សំខាន់ៗ និងស្ថិតិនានា។

ខ- បណ្តឹងតវ៉ាដែលអង្កេតឃើញចេញពីការប្រព្រឹត្តខុស ការបោកបញ្ឆោត ឬរបាយការណ៍ឧបទ្ទវហេតុប្រតិបត្តិការ និងវិធានការដែលបុគ្គលបរិស្ថានសាកល្បងបានចាត់ ដើម្បីដោះស្រាយឧបទ្ទវហេតុទាំងនោះ។

គ- វិធានការក្នុងការដោះស្រាយបណ្តឹងរបស់អតិថិជន។

ឃ- វិធានការក្នុងការគ្រប់គ្រងហានិភ័យដែលកើតមាន។

ង- វិធានការក្នុងការដោះស្រាយបញ្ហាផ្សេងៗពាក់ព័ន្ធនឹងការបំពេញតាមលក្ខខណ្ឌតម្រូវរបស់ **ន.ម.ក.**។

ច- ការស្នើសុំកែប្រែ ឬផ្លាស់ប្តូរបុគ្គលិកសំខាន់ៗ ថ្នាក់គ្រប់គ្រង របៀបដឹកនាំ ផែនការអាជីវកម្ម ឬបញ្ហាពាក់ព័ន្ធនឹងសាធនភាពហិរញ្ញវត្ថុរបស់បុគ្គលបរិស្ថានសាកល្បង។

ឆ- បញ្ហាពាក់ព័ន្ធផ្សេងទៀត។

កាតព្វកិច្ចនៃការផ្ដល់របាយការណ៍ និងព័ត៌មានលម្អិតជាក់លាក់ ត្រូវកំណត់ដោយ **ន.ម.ក.** ដោយពិចារណាទៅលើរយៈពេល ភាពស្មុគស្មាញ ទំហំនិងវិសាលភាព និងហានិភ័យពាក់ព័ន្ធនឹងការសាកល្បង។

មុននឹងទទួលយកអតិថិជន បុគ្គលបរិស្ថានសាកល្បងត្រូវបញ្ជាក់ជូនអតិថិជនថា ផលិតផល និងសេវាកម្មហិរញ្ញវត្ថុកំពុងដំណើរការនៅក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងពន្យល់ពីហានិភ័យសំខាន់ៗដែលពាក់ព័ន្ធនឹងផលិតផល និងសេវាកម្មហិរញ្ញវត្ថុនោះ ព្រមទាំងផ្ដល់ឯកសារពាក់ព័ន្ធជូនអតិថិជន។ បុគ្គលបរិស្ថានសាកល្បងត្រូវធានាថា អតិថិជនបានអានពេញលេញនូវឯកសារពាក់ព័ន្ធដែលផ្ដល់ដោយបុគ្គលបរិស្ថានសាកល្បង និងត្រូវទទួលបាននូវសេចក្ដីប្រកាសទទួលស្គាល់ហានិភ័យពីអតិថិជនដោយមានបញ្ជាក់ថាអតិថិជនបានអាននិងយល់ពីហានិភ័យទាំងនោះ។

បុគ្គលបរិស្ថានសាកល្បងត្រូវធានាថា អតិថិជនដែលចូលរួមក្នុងបរិស្ថានសាកល្បងទទួលបាននូវសិទ្ធិការពារដូចអតិថិជនចូលរួមនៅក្នុងទីផ្សារជាក់ស្ដែង (Live Market)។

**ន.ម.ក.** អាចចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងក្នុងដំណាក់កាលសាកល្បងនេះ។

## ៨-កាតព្វកិច្ចបន្ទាប់ពីដំណាក់កាលសាកល្បង

បុគ្គលបរិស្ថានសាកល្បងត្រូវផ្ដល់ជូន **ន.ម.ក.** នូវរបាយការណ៍បញ្ចប់ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីផុតរយៈពេលសាកល្បង ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយ **ន.ម.ក.** ដោយត្រូវមានព័ត៌មានដូចខាងក្រោម៖

ក- លទ្ធផលសំខាន់ៗ សូចនាករសមិទ្ធកម្មគន្លឹះ ធៀបនឹងសូចនាករដែលបានកំណត់សម្រាប់វាស់វែងភាពជោគជ័យ ឬបរាជ័យនៃការសាកល្បង និងការរកឃើញពីការសាកល្បង។

ខ- ប្រសិទ្ធភាពនៃប្រព័ន្ធសន្តិសុខសាយប័រ ដោយរួមបញ្ចូលទាំងកិច្ចគាំពារទិន្នន័យ, ឯកជនភាពនៃទិន្នន័យ, ការផ្ទុកទិន្នន័យ, ការទ្រទ្រង់ទិន្នន័យ និងការអនុវត្តនៃសន្តិសុខសាយប័រ។

គ- ប្រសិទ្ធភាពនៃប្រតិបត្តិការពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុ ក្រោមការសាកល្បង, អត្ថប្រយោជន៍នៃប្រតិបត្តិការពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុក្រោមការសាកល្បង និងសុវត្ថិភាពទ្រព្យសម្បត្តិរបស់អតិថិជន។

ឃ- របាយការណ៍ដំណោះស្រាយបណ្ដឹងរបស់អតិថិជន និងរបាយការណ៍ឧបទ្ទវហេតុទាំងអស់ប្រសិនបើមាន។

ង- មេរៀនសំខាន់ៗទាញចេញពីការសាកល្បង។

ច- ផែនការសម្រាប់ការផ្ទេរផលិតផលនិងសេវាកម្មហិរញ្ញវត្ថុក្រោមការសាកល្បង ពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុទៅក្នុងទីផ្សារជាក់ស្ដែង ក្នុងករណីការសាកល្បងទទួលបានជោគជ័យ។

ឆ- ព័ត៌មានផ្សេងទៀតដែលកំណត់ដោយ **ន.ម.ក.**។

បុគ្គលបរិស្ថានសាកល្បងត្រូវធានាថា រាល់កំណត់ត្រាពាក់ព័ន្ធនឹងការសាកល្បងត្រូវបានរក្សាទុកត្រឹមត្រូវសម្រាប់ការត្រួតពិនិត្យរបស់ **ន.ម.ភ.** និងត្រូវរក្សាទុកកំណត់ត្រាទាំងនេះក្នុងរយៈពេល ១០(ដប់) ឆ្នាំបន្ទាប់ពីកាលបរិច្ឆេទបញ្ចប់ការសាកល្បង ឬការចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

## ៩-ការចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

នៅចុងបញ្ចប់រយៈពេលនៃបរិស្ថានសាកល្បង ការបន្ធូរបន្ថយលើលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិរបស់ **ន.ម.ភ.** នឹងត្រូវផុតសុពលភាព ហើយបុគ្គលបរិស្ថានសាកល្បងត្រូវចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

នៅពេលចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ បុគ្គលបរិស្ថានសាកល្បងអាចឈានទៅដំណាក់កាលដាក់ឱ្យប្រើប្រាស់ក្នុងកម្រិតទូលំទូលាយនូវផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើងបាន លុះត្រាតែបុគ្គលបរិស្ថានសាកល្បងអាចបំពេញលក្ខខណ្ឌដូចខាងក្រោម៖

ក- **ន.ម.ភ.** យល់ឃើញថាអាចទទួលយកបាននូវលទ្ធផលដែលបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រេចបាន ធៀបនឹងលទ្ធផលរំពឹងទុក។

ខ- បុគ្គលបរិស្ថានសាកល្បងអាចបំពេញតាមលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិពាក់ព័ន្ធ។

បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុនឹងត្រូវបានបញ្ឈប់ក្នុងករណី៖

ក- **ន.ម.ភ.** មិនអាចទទួលយកបាននូវលទ្ធផលដែលបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុសម្រេចបាន ដោយផ្អែកលើសេណារីយ៉ូសាកល្បងចុងក្រោយ លទ្ធផលរំពឹងទុក និងកាលវិភាគដែលបានកំណត់។

ខ- បុគ្គលបរិស្ថានសាកល្បងមិនអាចបំពេញលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិពាក់ព័ន្ធនៅចុងបញ្ចប់រយៈពេលនៃបរិស្ថានសាកល្បង។ ប្រសិនបើស្ថានភាពបែបនេះត្រូវបានរំពឹងទុក បុគ្គលបរិស្ថានសាកល្បងត្រូវជូនដំណឹងមក **ន.ម.ភ.** ជាមុនឱ្យបានឆាប់។

គ- កំហុសត្រូវបានរកឃើញនៅក្នុងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុក្រោមការសាកល្បង ដែលបង្កជាហានិភ័យដល់អតិថិជន ឬប្រព័ន្ធហិរញ្ញវត្ថុ លើសពីអត្ថប្រយោជន៍នៃផលិតផលនិងសេវាកម្មហិរញ្ញវត្ថុក្រោមការសាកល្បង ហើយបុគ្គលបរិស្ថានសាកល្បងទទួលស្គាល់ថា កំហុសនេះមិនអាចដោះស្រាយបានក្នុងរយៈពេលនៃបរិស្ថានសាកល្បង។

ឃ- បុគ្គលបរិស្ថានសាកល្បងល្មើសនឹងលក្ខខណ្ឌណាមួយដែលបានកំណត់ក្នុងរយៈពេលនៃបរិស្ថានសាកល្បង។

ង- បុគ្គលបរិស្ថានសាកល្បងស្នើសុំការអនុញ្ញាតចាកចេញពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ។

មុនពេលចាកចេញពី ឬបញ្ចប់ដំណើរការបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ បុគ្គលបរិស្ថានសាកល្បងត្រូវធានាថា រាល់កាតព្វកិច្ចរបស់ខ្លួនចំពោះអតិថិជនពាក់ព័ន្ធនឹងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុក្រោមការសាកល្បង ត្រូវបានបំពេញ និង/ឬដោះស្រាយបានពេញលេញ។

**១០-ការដកហូតការអនុញ្ញាត**

**ន.ម.ក.** អាចដកហូតការអនុញ្ញាតពីបុគ្គលបរិស្ថានសាកល្បង ក្នុងករណីបុគ្គលបរិស្ថានសាកល្បង៖

ក- បរាជ័យក្នុងការកាត់បន្ថយហានិភ័យ ឬមិនអាចអនុវត្តវិធានការសុវត្ថិភាពតាមការតម្រូវ។

ខ- ផ្តល់ព័ត៌មានមិនពិតឬនាំឱ្យយល់ខុសឬមិនត្រឹមត្រូវ ឬបានបិទបាំងឬមិនបានបង្ហាញព័ត៌មានជាសារវន្តនៅក្នុងពាក្យស្នើសុំ។

គ- ប្រព្រឹត្តល្មើសច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ឃ- បាត់បង់កេរ្តិ៍ឈ្មោះ។

ង- ស្ថិតក្នុងនីតិវិធីជម្រះបញ្ជី។

ច- ល្មើសលក្ខខណ្ឌតម្រូវសុវត្ថិភាពទិន្នន័យ និងការរក្សាការសម្ងាត់។

ឆ- ធ្វើអាជីវកម្មតាមបែបផែនដែលធ្វើឱ្យខូចប្រយោជន៍ដល់អតិថិជនវិនិយោគិន និងសាធារណជន។

ជ- មិនអាចដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវកំហុសបច្ចេកទេស ចំណុចខ្សោយ ឬភាពងាយរងគ្រោះនៅក្នុងផលិតផល និងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង ដែលបង្កជាការអាក់ខាននៃផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ឬជាសកម្មភាពបោកបញ្ឆោត។

ឈ- មិនអាចបន្តអនុវត្ត ឬមិនអាចអនុវត្តតាមលក្ខខណ្ឌតម្រូវ ឬសេចក្តីណែនាំរបស់ **ន.ម.ក.**។

មុននឹងដកហូតការអនុញ្ញាត **ន.ម.ក.** ត្រូវ៖

ក- ព្យួរជាបន្ទាន់នូវការសាកល្បងចំពោះអតិថិជនថ្មី។

ខ- ជូនដំណឹងជាមុនដល់បុគ្គលបរិស្ថានសាកល្បងអំពីគោលបំណងនៃការដកហូតការអនុញ្ញាត។

គ- ផ្តល់ឱកាសដល់បុគ្គលបរិស្ថានសាកល្បងធ្វើការស្រាយបំភ្លឺជាមុនចំពោះការដកហូតការអនុញ្ញាត។

នៅពេលការអនុញ្ញាតត្រូវបានដកហូត បុគ្គលបរិស្ថានសាកល្បងត្រូវ៖

ក- អនុវត្តជាបន្ទាន់នូវផែនការចាកចេញ ដើម្បីបញ្ឈប់ការផ្តល់ផលិតផល និងសេវាហិរញ្ញវត្ថុដែលស្នើឡើង ជូនអតិថិជនថ្មី និងអតិថិជនមានស្រាប់។

ខ- ជូនដំណឹងដល់អតិថិជនអំពីការដកហូតការអនុញ្ញាតនេះ និងសិទ្ធិទទួលបានការដោះស្រាយបណ្តឹង។

គ- បំពេញកាតព្វកិច្ចដែលកំណត់ដោយ **ន.ម.ក.** ពាក់ព័ន្ធនឹងការរក្សាព័ត៌មានសម្ងាត់ រួមបញ្ចូលទាំងព័ត៌មានផ្ទាល់ខ្លួនរបស់អតិថិជនដែលទទួលបានក្នុងអំឡុងពេលសាកល្បង។

ឃ- ទូទាត់សំណងជូនអតិថិជនដែលរងការខាតបង់ហិរញ្ញវត្ថុ ដែលកើតចេញពីការសាកល្បងអនុលោមតាមវិធានការសុវត្ថិភាពរបស់បុគ្គលបរិស្ថានសាកល្បង។

ង- ផ្តល់ជូន **ន.ម.ក.** នូវរបាយការណ៍លើវិធានការដែលបានចាត់ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការដកហូតការអនុញ្ញាត។

ច- បំពេញលក្ខខណ្ឌតម្រូវផ្សេងទៀតតាមការកំណត់របស់ **ន.ម.ក.**។

## ១១-ការអនុវត្តវិធានការផ្សេងទៀត

បន្ថែមពីការដកហូតការអនុញ្ញាត វិធានការផ្សេងទៀតដែលមានចែងនៅក្នុងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ អាចត្រូវបានអនុវត្តចំពោះបុគ្គលបរិស្ថានសាកល្បង ក្នុងករណីបុគ្គលបរិស្ថានសាកល្បងបានធ្វើសកម្មភាពដូចខាងក្រោម៖

ក- ល្មើសគោលការណ៍ស្គាល់អតិថិជន។

ខ- ល្មើសគោលការណ៍ឯកជនភាពរបស់អតិថិជន។

គ- ជំរុញឱ្យមានការលក់នូវផលិតផល ឬសេវាកម្មខុសច្បាប់ ឬបោកបញ្ឆោត។

ឃ- ជំរុញឱ្យមានការលក់នូវផលិតផល ឬសេវាកម្មដោយផ្អែកលើការផ្តល់យោបល់ដែលនាំឱ្យយល់ខុស។

ង- ល្មើសបទប្បញ្ញត្តិពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

ច- បង្កើតឱ្យមានហានិភ័យចំពោះស្ថិរភាពហិរញ្ញវត្ថុ។

ឆ- រំលោភបំពានកម្មសិទ្ធិបញ្ញា។

## ១២-កម្រៃ

ពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត ថ្លៃការអនុញ្ញាត កម្រៃសេវាលើប្រតិបត្តិការ និងកម្រៃសេវាលើការស្នើសុំពន្យារពេល ការផ្លាស់ប្តូរ ឬកែប្រែផ្សេងៗត្រូវកំណត់ដោយ **ន.ម.ក.** ដោយផ្អែកលើបុគ្គលដាក់ពាក្យស្នើសុំ ការស្នើសុំរបស់បុគ្គលដាក់ពាក្យស្នើសុំ និងផលិតផលនិងសេវាកម្មហិរញ្ញវត្ថុដែលស្នើឡើង។

ថ្ងៃ ចន្ទ ៦ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែ សីហា ឆ្នាំ២០២៣

**និយ័តករមូលបត្រកម្ពុជា**

# ឧបសម្ព័ន្ធ១ ស្តីពីដំណើរការនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតចូលរួមក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

## នៃគោលការណ៍ណែនាំលេខ...០០៩/២៣ ន.ធ.ក/គ.ណ.ន...ចុះថ្ងៃទី...០៧...ខែ...សីហា...ឆ្នាំ២០២៣

## ស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ



## ឧបសម្ព័ន្ធ២ ស្តីពីគំរូនៃភាពបត់បែននៃលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិ និងការរំពឹងទុកសម្រាប់បរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ

## នៃគោលការណ៍ណែនាំលេខ...០០៩/២៣ ន.ម.ក/គ.ណ.ន...ចុះថ្ងៃទី...០៧...ខែ...សីហា...ឆ្នាំ២០២៣

## ស្តីពីបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ

តារាងខាងក្រោមគឺជាគំរូនៃលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិសម្រាប់ការពិចារណាក្នុងការស្នើសុំការបន្ធូរបន្ថយ ក្នុងអំឡុងពេលនៃបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុ និងជាគំរូនៃលក្ខខណ្ឌតម្រូវនៃបទប្បញ្ញត្តិដែល **ន.ម.ក.** តម្រូវឱ្យរក្សាការអនុវត្ត។

| គំរូនៃលក្ខខណ្ឌតម្រូវដែលត្រូវរក្សាការអនុវត្ត |
|---|
| - ការរក្សាការសម្ងាត់នៃព័ត៌មានរបស់អតិថិជន |
| - លក្ខខណ្ឌវិនិច្ឆ័យត្រឹមត្រូវនិងសមស្រប ជាពិសេសលើភាពស្មោះត្រង់ និងភាពសុចរិត |
| - ការថែរក្សានិងគ្រប់គ្រងសាច់ប្រាក់ និងទ្រព្យសម្បត្តិរបស់អតិថិជនដោយក្រុមហ៊ុនអន្តរការី |
| - ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម |
| - ការត្រួតពិនិត្យហានិភ័យ |
| - គោលការណ៍ស្គាល់អតិថិជន |

| គំរូនៃលក្ខខណ្ឌតម្រូវដែលអាចស្នើសុំបន្ធូរបន្ថយ |
|---|
| - លក្ខខណ្ឌតម្រូវរក្សាទ្រព្យសកម្ម |
| - សមាសភាពក្រុមប្រឹក្សាភិបាល |
| - សមតុល្យសាច់ប្រាក់ |
| - ការវាយតម្លៃលទ្ធភាពសង |
| - ភាពរឹងមាំហិរញ្ញវត្ថុ |
| - កម្រិតសាធនភាព និងភាពគ្រប់គ្រាន់នៃដើមទុន |
| - ថ្លៃអាជ្ញាបណ្ណ |
| - បទពិសោធន៍នៃគណៈគ្រប់គ្រង |
| - ទ្រព្យសកម្មសន្ទនីយភាពអប្បបរមា |
| - ដើមទុនអប្បបរមា |
| - កេរ្តិ៍ឈ្មោះ |
| - កំណត់ត្រាសមិទ្ធកម្ម |